ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍
# ប្រជុំរួមប្រចាំខែឧសភា ឆ្នាំ២០២១
# របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០ នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន ទីប្រឹក្សា ជំនួយការ អគ្គលេខាធិការ-រង លោក លោកស្រី អ្នកនាងកញ្ញា ជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ចូលរួមតាមបណ្តាញវីដេអូកម្មវិធី Zoom សរុបចំនួន៥០នាក់/គណនី។

## គោលបំណងនៃកិច្ចប្រជុំដើម្បី:

- ធ្វើបច្ចុប្បន្នភាពនៃសកម្មភាពរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ស្ថានភាពរាលដាល និងគោលដៅនៃការឆ្លើយតបនឹងមេរោគអេដស៍ និងបទអន្តរាគមន៍។
- សមិទ្ធផលដែលសម្រេចបាន និងឧបសគ្គ ក្នុងការអនុវត្តផែនការសកម្មភាព និងផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ប្រចាំខែឧសភា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉េត។
២- បទបង្ហាញ ស្តីពីការឆ្ពោះទៅកាន់ការចូលរួមក្នុងកិច្ចប្រជុំអង្គការសហប្រជាជាតិស្តីអំពីជំងឺអេដស៍ឆ្នាំ២០២១
៣- មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី
៤- កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែឧសភា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែមិថុនា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញ ដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

## I- **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

### ១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្ររៀបចំផែនការ វិធីសាស្ត្រគ្រប់គ្រងទិន្នន័យ និងវិធីសាស្ត្ររៀបចំព័ត៌មាន។
- ជាវាគ្មិនស្តីពីការចូលរួមអបអរសប្តាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នា និងទិវាអន្តរជាតិប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥

### ២- បញ្ហាប្រឈម ៖

- ស្ថានភាពជំងឺកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- មិនអាចផ្តល់សេវាអប់រំដោយផ្ទាល់បាន។
- មិនអាចចុះទៅជំរុញការងារ ***FTC*** នៅតាមខេត្តគោលដៅបាន។

### ៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ត្រៀមចូលរួមកិច្ចប្រជុំជាន់ខ្ពស់ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦។
- ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ នាថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥។
- បន្តវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពការងារដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ។

## II- **បទបង្ហាញ *ស្តីពីការឆ្ពោះទៅកាន់ការចូលរួមក្នុងកិច្ចប្រជុំអង្គការសហប្រជាជាតិស្តីអំពីជំងឺអេដស៍ ឆ្នាំ២០២១*** ដោយឯកឧត្តម វេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

- កិច្ចប្រជុំជាន់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ នឹងកោះប្រជុំចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក តាមបណ្តាញវីដេអូ។
- ឯកសារ២០២១ Political Declaration on HIV and AIDS បានចែងដូចគ្នានឹងឯកសារនៅឆ្នាំ២០១៦ ដែរ អំពីយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ ដូចជា អ្នកប្រើគ្រឿងញៀន អ្នករកស៊ីផ្លូវភេទ និងអ្នកស្រលាញ់ភេទដូចគ្នា។
- របៀបវារៈនៃកិច្ចប្រជុំជាន់ខ្ពស់ មាន៥ចំណុចសំខាន់ៗ ៖
  - ➢ ការដោះស្រាយវិសមភាពដើម្បីបញ្ចប់ជំងឺអេដស៍៖ ១០ឆ្នាំ ទៅដល់ឆ្នាំ២០៣០។
  - ➢ ដាក់មនុស្ស និងសហគមន៍ នៅចំណុចកណ្តាលនៃការឆ្លើយតបនឹងជំងឺអេដស៍។
  - ➢ ធនធាន និងថវិកា សម្រាប់ការឆ្លើយតបនឹងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព។
  - ➢ ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី និងក្មេងស្រី ក្នុងការឆ្លើយតបនឹងជំងឺអេដស៍។
  - ➢ ដោះស្រាយផលប៉ះពាល់នៃជំងឺកូវីត១៩ លើការឆ្លើយតបនឹងជំងឺអេដស៍ និងការកសាងត្រឡប់មកវិញល្អប្រសើរ ត្រៀមខ្លួនចំពោះរាគត្បាត។

- ជំងឺកូវីដ-១៩ នៅតែជាបញ្ហា ដែលយើងមិនទាន់អាចចុះបេសកកម្មបាន ជាហេតុបណ្តាលឱ្យមានផលប៉ះពាល់សកម្មភាពសម្រាប់ត្រីមាសទី៣ និងត្រីមាសទី៤។
- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អំពាវនាវដល់ជនរួមជាតិទាំងអស់ឱ្យចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងចរន្តជាតិតែមួយឆ្ពោះទៅការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥
- ស្របតាមគោលការណ៍ដែល *"មិនទុកនរណាម្នាក់ចោល"* យើងប្តេជ្ញាអនុវត្តអភិក្រមដែលផ្តោតលើការយកប្រជាពលរដ្ឋជាគោល។
- គោលនយោបាយ និងកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាការធានាវិសាលភាពគ្របដណ្តប់សុខភាពសកល ការគាំពារសង្គម និងកិច្ចខិតខំប្រឹងប្រែងដទៃទៀតដែលសំដៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។
- លើកគម្រោងថវិកា៨០លាន រៀលក្នុងខេត្តនីមួយៗដែលផ្តល់ជូន *គម្រោងទីក្រុងពន្លឿនការឆ្លើយតប* (Fast Track City "PNP, BBG, BMC SRP" ) ដើម្បីអនុវត្ត សជណ ២១៣ នៅថ្នាក់ ក្រោមជាតិ។

### III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- ករណីក្រុមបុរសរួមភេទជាមួយបុរស ដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវគិតគូជួបពិភាក្សាគ្នា និងសិក្សាជាមួយដៃគូគ្រប់លំដាប់ថ្នាក់ ដើម្បីរកវិធីដោះស្រាយ និងទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍។

២- ឯកឧត្តម លោកជំទាវដែលទទួលបន្ទុកក្រសួង និងខេត្ត ត្រូវណែនាំដល់ថ្នាក់ក្រសួង និងខេត្តឱ្យបន្តអនុវត្ត ស.ជ.ណ. លេខ២១៣ ដើម្បីឆ្ពោះទៅទប់ស្កាត់ការចម្លងថ្មី និងត្រូវរៀបចំផែនការសកម្មភាពអាទិភាពឱ្យស្របគ្នានឹងគោលការណ៍នយោបាយយុទ្ធសាស្ត្រនីមួយៗ ដើម្បីឈានទៅរកភាពជោគជ័យនៃការប្រយុទ្ធនឹងជំងឺអេដស៍។

៣- ចំពោះកញ្ចប់ផែនការសកម្មភាពថវិកា៨០លានរៀល សម្រាប់ខេត្ត *គម្រោងទីក្រុងពន្លឿនការឆ្លើយតប* ( Fast Track City) រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ គឺគោលដៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ផ្តល់ជូនទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដើម្បីមានថវិកាសម្រាប់ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍។

៣- ក្រសួងនីមួយៗត្រូវធ្វើការងារជំងឺអេដស៍ទៅតាមតួនាទីរបស់ខ្លួន ដូចជាសកម្មភាពរបស់ក្រសួងការបរទេស បានរៀបចំគណៈប្រតិភូ សម្រាប់កិច្ចប្រជុំនៅអង្គការសហប្រជាជាតិ បញ្ចូលខ្លឹមសារនៃសេចក្តីថ្លែងការរបស់កម្ពុជាក្នុងសម័យប្រជុំជាដើម។

៤- កិច្ចប្រជុំជាន់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ គឺជាកិច្ចប្រជុំបន្តពីកិច្ចប្រជុំឆ្នាំ២០១៦ ដែលមានគណៈប្រតិភូកម្ពុជាជាច្រើនរូបបានអញ្ជើញទៅចូលរួម ហើយរៀបចំរាល់៥ឆ្នាំម្តងរហូតដល់ឆ្នាំ២០៣០។

៥- ក្នុងអង្គប្រជុំ មានសេចក្តីថ្លែងការណ៍ជាច្រើនចំណុចណាស់ ចំណុចខ្លះធ្វើឱ្យមានការរើសើប ដូចជាសិទ្ធមនុស្ស និងការរើសអើង។ ឆ្លើយតបតាមមតិរបស់អង្គការសិទ្ធមនុស្ស សេចក្តីថ្លែងការណ៍នយោបាយមាន៣ចំណុច ទី១). ចង់ឱ្យប្រទេសទាំងអស់កុំឱ្យដាក់ទោសលើអ្នកប្រើគ្រឿងញៀន ទី២). កុំឱ្យដាក់ទោសលើស្ត្រីបម្រើសេវាកម្សាន្ត ទី៣). កុំឱ្យដាក់ទោសចំពោះការរៀបអាពាហ៍ពិពាហ៍រវាងមនុស្សដែលមានភេទដូចគ្នា។ មានប្រទេសខ្លះដែលមានច្បាប់តឹង

តែងមិនគាំទ្រនូវសេចក្តីថ្លែងការណ៍ គោលនយោបាយរបស់អង្គការសហប្រជាជាតិដែលបានដាក់នោះទេ ហើយប្រទេសខ្លះបានទាមទារឱ្យប្រទេសកម្ពុជាគាំទ្រគាត់។

៦- គោលជំហររបស់ប្រទេសកម្ពុជា គឺគាំទ្រកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ៖

ទី១)- កម្ពុជាកំពុងតែអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) មានដូចជា៖

- កម្មវិធីចែកម្ជុលសឺរ៉ាំង ដែលបានអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលជាអ្នកចែកចាយដល់អ្នកចាក់គ្រឿងញៀន ដើម្បីទប់ស្កាតការរីករាលដាលមេរោគអេដស៍ កាន់តែខ្លាំងថែមទៀត។
- កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ដល់ប្រជាជនគន្លឹះ។ កម្មវិធីនេះ ត្រូវបាន**សម្តេចតេជោ** ប្រកាសឱ្យប្រើប្រាស់តាំងពីឆ្នាំ១៩៩៩។

ទី២)- កម្ពុជាមិនដាក់ទោសអ្នកប្រើប្រាស់គ្រឿងញៀន ដែលប្រើក្នុងចំនួនបន្តិចបន្តួច ព្រមទទួលយកការព្យាបាល និងស្តារនីតិសម្បទារ (មាត្រា ១០៥ និង ១០៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)។

ទី៣)- កម្ពុជាពុំមានច្បាប់ណាដែលផ្តន្ទាទោស អ្នកស្រឡាញ់ភេទដូចគ្នា ឬអ្នករួមភេទជាមួយអ្នកមានភេទដូចគ្នា (SMS) និងអ្នកបំប្លែងភេទ (TG) ឡើយ។

ទី៤)- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានចែងអំពីទោសទណ្ឌលើអំពើពេស្យាចារទេ បើគ្មានអំពើអូសទាញក្នុងទីសាធារណៈ រឺសញ្ញារកម្ម (មាត្រា ២៣, ២៤, ២៥ និង២៦)។

ទី៥)- កម្ពុជាមិនផ្តន្ទាទោសអ្នកជំងឺអេដស៍ទេ ប្រសិនការឆ្លងនោះកើតឡើងដោយអចេតនា (មាត្រា១៨ នៃច្បាប់ស្តីពីការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍។

៧- កិច្ចប្រជុំថ្ងៃទី០៣ ០៦ ២០២១ ដើម្បីធ្វើបច្ចុប្បន្នភាព សម្រាប់សមាជិកគណៈប្រតិភូឱ្យបានដឹងពីដំណើរការនៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ សូមឯកឧត្តម **ទា ផលា** ធ្វើបទបង្ហាញអំពីកម្មវិធីអេដស៍ វឌ្ឍនភាព បញ្ហាប្រឈម យុទ្ធសាស្ត្រជាតិលើកទី៥ និងស.ជ.ណ២១៣។

៨- ការឧបត្ថម្ភដល់ក្រុមគ្រួសារ ឬបុគ្គលដែលមានអ្នកផ្ទុកមេរោគអេដស៍ មិនត្រូវរក្សាការសម្ងាត់ចំពោះអ្នកផ្តល់សេវា ឬគ្រូពេទ្យព្យាបាលនោះទេ។ ការរក្សាការសម្ងាត់ គឺធ្វើតែចំពោះមនុស្សទូទៅនៃស្ថានភាពសង្គម ឬភូមិសាស្ត្រ បើសង្គមមានការប្រកាន់ ឬមានការរើសអើងខ្លាំង។

៩- កម្ពុជាបានឱ្យតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើជា*ប្រធានគណៈកម្មាធិការសម្រួលមូលនិធិសកលប្រចាំកម្ពុជា* (CCC) ដើម្បីភ្ជាប់ឱ្យបាននូវសេចក្តីត្រូវការនៃកម្មវិធីជំងឺអេដស៍ និងដឹងពីបញ្ហាសុខភាពសាធារណៈ ដឹងពីបញ្ហាប្រឈម និងសំណូមពរ ដើម្បីរកវិធីគាំពារដល់សង្គម។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានកោតសរសើរ ដល់ថ្នាក់ដឹកនាំទាំងអស់ ដែលមានការទំនាក់ទំនងគ្នាបានល្អ រវាងថ្នាក់ដឹកនាំបច្ចេកទេស និងអគ្គលេខាធិការដ្ឋាន ដោយមានការឯកភាពគ្នាជាធ្លុងមួយ និងបន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យបានកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១: ១៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១
អ្នកធ្វើកំណត់ហេតុ

ស៊ុត_ថេងផាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី